**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿង រដ្ឋប្បវេណី
លេខ: ២២៦
ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០០
**សាលដីកា**
លេខ: ២៣៩
ចុះថ្ងៃទី ២១ ខែវិច្ឆកា ឆ្នាំ ២០០០

តាងនាមប្រជារាស្ត្រខ្មែរ
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែ វិច្ឆកា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ........... ជាចៅក្រមរបាយការណ៍
៤-លោក ............. ជាចៅក្រម
៥-លោក .............. ជាចៅក្រម
**ក្រឡាបញ្ជី**
-លោក ...................
**តំណាងមហាអយ្យការ**
-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកា៤៣ (ក) ចុះថ្ងៃទី២៥ខែមេសា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥១ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ធវណ ភេទ ស្រី អាយុ ៣៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរលក់ដូរ មានទីលំនៅ ភូមិប៉ាល់លេយ្យ ឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ។
ឪពុកឈ្មោះ ធ ការ "ស" ម្តាយឈ្មោះ ហូ ហូវ "ស" ប្តីឈ្មោះ ស៊ុន សម្បត្តិ ។

មានមេធាវីលោក ..............

និងចុងបណ្តឹងសាទុក្ខឈ្មោះ ងវន ភេទប្រុស អាយុ ៣៧ ឆ្នាំ ជាត់ខ្មែរ មុខរបរ លក់ដូរ ទីលំនៅភូមិប៉ាលលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ងិន តែស្រីម (ស) ម្តាយឈ្មោះ ហេង (រ) ប្រពន្ធឈ្មោះ យក់ សុវណ្ណា ។

មានមេធាវីលោកស្រី ...........

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារប្រាក់

បានឃើញបណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០០ របស់អ្នកស្រី ធ វណ្ណា បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ៤៣ (ក) ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៦ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩ ដើមចោទ ឈ្មោះ ធ វណ្ណា ប្តឹងទាមទារប្រាក់ចំនួន ២.២៤៨.៦៨៥ បាត ដោយហេតុថា ឈ្មោះ ងវន និង ប្រពន្ធបានទិញដូងរបស់ខ្លួនជឿមិនព្រមសង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៨០ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យប្តឹងចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះ ធ វណ្ណា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឲ្យឈ្មោះ ងវន និងប្រពន្ធឈ្មោះ យក់ សុវណ្ណា សងប្រាក់ថ្លៃដូងដែលខ្លួន បានចុះកិច្ចសន្យាកាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ១៩៩៩ ចំនួន ២.២៤៨.៦៨៥ បាត (ពីរលានពីរយសែសិបប្រាំបីពាន់ប្រាំមួយរយប៉ែតសិបប្រាំបាត)នោះទៅឈ្មោះ ធ វណ្ណា ជាដើមចោទវិញតាមការសន្យា ។បើករណីរឹងរូសមិនព្រមសងប្រាក់នេះ ទៅដើមចោទទេ ឲ្យរឹបអូសទ្រព្យសម្បត្តិ និងដាក់គុកបង្ខំរូបកាយដើម្បីធានាសំណងតាមបញ្ញត្តិច្បាប់ ។

៣-ឲ្យឈ្មោះ ងវន និងប្រពន្ធសងប្រាក់ប្រដាប់ក្តី ៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយនោះទៅដើមចោទវិញ និងឲ្យបង់ពន្ធសមាមាត្រក្នុងមួយភាគរយលើចំនួនប្រាក់ត្រូវសង ២.២៤៨.៦៨៥ បាត ស្មើ ២២.៤៨៦ បាត (ម្ភៃពីរពាន់បួនរយប៉ែតសិបប្រាំមួយបាត) ។

សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូភាគី ទុកសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេលពីរខែ គិតពីថ្ងៃទីប្រកាសសាលក្រម ។

បានឃើញ សាលដីការបៀបលេខ ៩៤ ចុះថ្ងៃទី ០៤ ខែវិច្ឆកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចចាត់របៀបៈ

បញ្ជូលសាក្សីដើមបណ្តឹងឧទ្ធរណ៍ ដើម្បីធ្វើអង្កេតសាកសួរ ។

បានឃើញ សាលដីកាកំបាំងមុខលេខ ៤ (ក) ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តី សម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ឈ្មោះ ងវន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ ៨០ ចុះថ្ងៃទី ១៤ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យចោលជាអសាបង់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ មានសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០០ របស់លោក ............. មេធាវីការពារឲ្យដើមចោទ ដែលប្តឹងជំទាស់នឹងសាលដីកាលេខ ៤ (ក) ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ ៤៣ (ក) ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ០៧ កុម្ភៈ ឆ្នាំ២០០០ របស់មេធាវី ............. ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤ (ក) ចុះថ្ងៃទី ០៦ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃទីទទួលលិខិតជូនដំណឹងនេះ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៦១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់អ្នកស្រី ធ វណ្ណា បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៣ (ក) ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះ ធ វណ្ណា

បានឃើញសារណាតប ចុះថ្ងៃទី ០៩ ខែសីហាឆ្នាំ២០០០ របស់ឈ្មោះ ងវន

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថាៈ

-បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

-សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គង ទាំងទម្រង់ ទាំងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ឆ វណ្ណា ជាម្ចាស់បណ្តឹងសាទុក្ខ

បានស្តាប់ចម្លើយរបស់ឈ្មោះ ងវន ជាចុងបណ្តឹងសាទុក្ខ ឆ្លើយថាៈ ខ្លួនបានរកស៊ីជាមួយគាត់ជាយូរណាស់មកហើយ មិនដែលធ្វើកិច្ចសន្យាអ្វីទេ គឺទូទាត់ជាបណ្តើរៗ តាមទឹកប្រាក់ដែលបានទិញនោះ ។

នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៩ ខ្លួនបានលក់ផ្លែដូងឲ្យថ្លៃចំនួន ១៣៧.៣៥១ ថ្លៃផ្លែដូងទាំងនោះត្រូវបានពួកថៃបោកអស់ ដោយដឹងថា ខ្លួនត្រូវបានគេបោកអស់ ឆ វណ្ណា ក៏បានមកត្រួតពិនិត្យមើលផ្លែដូងក្នុងឃ្លាំងរបស់ខ្លួនក៏ឃើញនៅសល់គ្រប់ចំនួន បន្ទាប់មកគាត់ក៏ទៅហៅខ្លួនធ្វើកិច្ចសន្យាក្រោយមក ឆ វណ្ណា ប្រាប់ឲ្យខ្លួនទៅរកជនជាតិថៃ នោះឆ្លៀតពេលនោះ ឆ វណ្ណា បាននាំគ្នាទៅដឹកផ្លែដូងពីឃ្លាំងរបស់ខ្លួននៅយប់ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ១៩៩៩ អ្នកយាមឃ្លាំងបានទូរស័ព្ទប្រាប់ខ្លួនៗ បានប្រាប់ថា ចាំខ្លួនទៅសិន តែពួក ឆ វណ្ណា មិនព្រមស្តាប់សោះ បើគិតតាមចំនួនដែលគាត់បានដឹកទៅនោះ គាត់ត្រូវនៅជំពាក់ខ្លួនវិញ រីឯក្រដាស់ស្នាមដែលគាត់ព្រមទទួលស្គាល់នៅ គាត់មិនដាក់ទៅតុលាការទេ ចំណែកកិច្ចសន្យាដែលចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៩៩ ខ្លួនមិនទទួលស្គាល់ទេ ព្រោះពេលនោះធ្វើការទូទាត់មិនត្រឹមត្រូវ ។

មេធាវីលោក ............. ធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីរបស់ខ្ញុំបាទពិតជាបានលក់ចំនួនពីរសែន ប្រាំម៉ឺនពីរពាន់ប្រាំបួនរយហាសិបបួនផ្លែ តាមកិច្ចសន្យាប្រាកដមែន ដែលសុទ្ធតែមានស្នាមមេដៃទទួលស្គាល់ទាំងអស់ ដូច្នេះឈ្មោះ ងវន បានទទួលថា ការជំពាក់ប្រាក់ចំនួនពីរលានពីសែនបួនម៉ឺនប្រាំបីពាន់ ប្រាំមួយរយប៉ែតសិបប្រាំបាត ពីកូនក្តីរបស់ខ្ញុំបាទប្រាកដណាស់ ។ឯសាក្សីទាំងអស់គឺឆ្លើយដោយស្រពិចស្រពិល ដែលមិនអាចយកជាការបានឡើយ ។តាមលិខិតលេខ ៤៩៦/៩៩ របក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់ប៉ុស្តិ៍នគរបាលច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតបានបញ្ជាក់ថា ពុំឃើញមានជនទាំងប្រាំនាក់នេះ ចេញពីប្រទេសនៅថ្ងៃណាមួយ តាមច្រកទ្វានេះទេ លិខិតលេខ ២២០រ បឧ ចុះថ្ងៃទី ១៤ខែធ្នូឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។មិនតែប៉ុណ្ណោះលិខិតរបស់សាលាឧទ្ធរណ៍លេខដដែលនេះ មានការកោសលុបឲ្យទៅតាមច្រកស្មៀងទៅវិញ ។

សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ គឺមានការយល់ឃើញពីការពិតទាំងអស់គឺបានបំពាននឹងគតិច្បាប់ទាំងស្រុង ម្យ៉ាងវិញទៀតការសម្រេចនេះ ដោយយករឿងព្រហ្

ទណ្ឌមកធ្វើជាការទូទាត់ជាមួយកកិច្ចសន្យាទៅវិញ សូមឯកឧត្តមមេត្តាពិនិត្យ និងពិចារណា និងសូមបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

មេធាវី អ្នកស្រី ពីង ធីតា បានធ្វើសេចក្តីសន្និដ្ឋានថាៈ ការរកស៊ីរវាងឈ្មោះ ធ វណ្ណា និងកូនក្តីរបស់នាងខ្ញុំគឺ រកស៊ីដោយមានការទុកចិត្តគ្នាទៅវិញទៅមក ដោយធ្វើការទូទាត់គ្នាតាមក្រោយ អ្នកស្រី ធ វណ្ណា បានដឹងដូងមកដាក់ឃ្លាំងកូនក្តីរបស់នាងខ្ញុំមែន លុះឮថាជនជាតិថៃបោកអស់ អ្នកស្រី ធ វណ្ណា ក៏បានមករាប់ដូងដែលនៅក្នុងឃ្លាំងឃើញថា គ្រប់ចំនួន ក្រោយមកគាត់ប្រាប់ឲ្យកូនក្តីរបស់នាងខ្ញុំរកជនជាតិថៃនោះ និងធ្វើកិច្ចសន្យាដោយមានការទុកចិត្តព្រោះពេលរាប់ទៅឃើញថា នៅគ្រប់ចំនួន ផ្លែដូងទាំងនោះក៏ស្ថិតនៅក្នុងឃ្លាំងខ្លួនទៀត ក៏សុខចិត្តទទួលស្គាល់កិច្ចសន្យានោះ ។

ឆ្លៀតពេលដែលកូនក្តីរបស់នាងខ្ញុំមិននៅ ពួកអ្នកស្រី ធ វណ្ណា នាំគ្នាមកដឹកជញ្ជូនដូងចេញដោយមានសាក្សីដឹងឮនៅពេលនោះ ប្រាំនាក់បានឆ្លើយដូចៗគ្នាថា អ្នកស្រី ធ វណ្ណា បានទៅដឹកដូងពិតមែន ព្រមទាំងមានលិខិតជាច្រើន សុទ្ធតែបានបញ្ជាក់យ៉ាងច្បាស់ថា អ្នកស្រី ធ វណ្ណា បានឆ្លងចូលទៅប្រទេសថៃពិតមែន ដូច្នេះអ្នកស្រី ធ វណ្ណា មិនអាចប្រកែកបានឡើយ ព្រោះមានសាក្សី មានលិខិតបញ្ជាក់ និងមានភស្តុតាងគ្រប់សព្វអស់ហើយ ។

អាស្រ័យហេតុដូច្នេះ សូមឯកឧត្តមមេត្តាតម្កល់សាលដីកា របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អ្នកស្រី ធ វណ្ណា ចម្លើយដោះសាររបស់លោក ងវន និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០០ របស់អ្នកស្រី ធ វណ្ណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធសាលាក្រមរដ្ឋប្បវេណីលេខ ៨០ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យចោល ហើយពុំបានសម្រេចអំពីបណ្តឹងដើមរបស់អ្នកស្រី ធ វណ្ណា នោះបានន័យថា សាលាឧទ្ធរណ៍ពុំបានសម្រេចដល់អង្គសេចក្តីឡើយ ។

-យល់ឃើញថា សាលាឧទ្ធរណ៍ក៏បានទទួលស្គាល់ដែរថា កិច្ចសន្យាចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៩ របស់គូភាគីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរ ប៉ុន្តែសាលាឧទ្ធរបែរជាសម្រេចបដិសេធសាល

ក្រមរបស់តុលាការខេត្តមានជ័យ ដែលសម្រេចឲ្យចុងចម្លើយសងប្រាក់ទៅដើមចោទ តាមកិច្ចសន្យានេះទៅវិញ ។

-យល់ឃើញថា ក្នុងករណីដែលសាលាឧទ្ធរណ៍ យល់ថាការសម្រេចបដិសេធសាលក្រមរបស់តុលាការខេត្តបន្ទាយមានជ័យចោល មានន័យថា លើកបណ្តឹងដើមរបស់អ្នកស្រី ធ វណ្ណា ចោល ហើយ ឲ្យចុងចម្លើយគឺលោក ងវន រួចផុតពីកាតព្វកិច្ច នៃកិច្ចសន្យា ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ១៩៩៩ ដោយសំអាងទៅលើភស្តុងតាងថា មានអំពើរឹបអូសថ្លៃដូងនៅប្រទេសថៃ កាលពីយប់ថ្ងៃទី១៧ខែមីនា ឆ្នាំ១៩៩៩ ដែលជាភស្តុតាងនៃបទល្មើព្រហ្មទណ្ឌនោះជាការភ័ន្តច្រឡំ ពីព្រោះពុំមានសាលក្រម ឬ សាលដីកាណាមួយសម្រេចផ្តន្ទាទោស អំពើល្មើស និងជនល្មើសដែលបានប្រព្រឹត្តនៅយប់ថ្ងៃទី ១៧ខែមីនា ឆ្នាំ១៩៩៩ នោះនៅឡើយ ហើយតាមបញ្ញាតិ នៃត្រា១២ និង១៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ លោក ងវន នឹងអាចទទួលសំណងជម្ងឺចិត្ត បានលុះណាតែអំពើល្មើស និងជនល្មើសនោះ ត្រូវបានផ្តន្ទាទោស ។ ក្នុងរឿងក្តីនេះ អំពើល្មើស ឬ ជនល្មើស ដែលបានប្រព្រឹត្តនៅយប់ថ្ងៃទី ១៧ខែមីនា ឆ្នាំ១៩៩៩ ពុំបានត្រូវផ្តន្ទាទោសទេ ដូច្នេះកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ នៅមានតម្លៃដដែល ។

-យល់ឃើញថា អ្នកស្រី ធ វណ្ណា បានធ្វើសារណាការពាររឿងក្តីរបស់អ្នកស្រី ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះ រឿងនេះកំបាំងមុខអ្នកស្រីប៉ុន្តែចាត់ទុកជាចំពោះ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៣ (ក) ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខលោក ងវន កំបាំងមុខអ្នកស្រី ធ វណ្ណា

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០០ របស់អ្នស្រី ធ វណ្ណា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៤៣ (ក) ចុះថ្ងៃទី២៥ ខែមេសា ២០០០ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២២៦ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ដាប់ក្តីចំនួន ១៩០០០៛ ដែលអ្នកស្រី ធ វណ្ណា បានបង់រួចហើយគឺះ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ ។

ហើយតម្រូវឲ្យលោក ងវន សងប្រាក់ចំនួន ១៩០០០៛ នេះទៅអ្នកស្រី ធ វណ្ណា វិញ ។

៥-សាលដីកានេះ ជំនុំជំរះ ថ្ងៃទី ២១ ខែវិច្ឆកា ឆ្នាំ២០០០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ខែវិច្ឆកា ឆ្នាំ២០០០ ។